មេទ័ពបានមកវិលវិញហើយទូលថ្វាយព្រះអង្គថា ព្រះចៅអធិរាជដ៏មានឫទ្ធិ តាមពិតទៅពន្លឺចង្កៀងដែលដោយឆេះនៅឡើយ គឺជាវត្តមានមនុស្សស្រីវ័យក្មេងម្នាក់នាងកំពុងតែជាប់រវល់ត្បាញរវៃ។

ព្រះចៅអធិរាជក៏ចងចិញ្ចើមហើយសួរវិញថា តើកូនចៅអ្នកណាត្រូវបង្គាប់ឲ្យមកធ្វើតម្បាញវេលាថ្មើរណេះ?

មេទ័ពក៏បានឆ្លើយតបថា នាងគឺជាកូនស្រីភរិយាដើមនៃម្ចាស់ផ្ទះធំក្បែរនោះឈ្មោះ សាវ៉ាឌី។ ឪពុកម្តាយរបស់នាងដើមឡើយគឺជាអ្នកមានទ្រព្យសម្បត្តិធ្វើជំនួញជួញដូរ ក្រោយមកម្តាយនាងបានស្លាប់ដោយជំងឺ នាងត្រូវបានផ្ទុងផ្តើមធំឡើងក្រោមដៃម្តាយចុងពីរនាក់។

ដោយសារតែនាងគឺជាកូនដើម មានរូបសម្រស់និងស្លូតបូតពេក តែងរងទុក្ខបុកម្នេញ ត្រូវគេប្រើឲ្យធ្វើការសព្វសារពើ គឺមិនអាចរស់ដោយសុខស្រួលដូចជាអ្នកនាងដទៃនោះឡើយ។

ជារៀងរាល់យប់នៅពេលដែលអ្នកផ្សេងគេបានចូលនិទ្រានាងតែងតែមានភារៈកិច្ចដើម្បីត្បាញក្រណាត់សម្រាប់លក់ផ្គត់ផ្គង់គ្រួសារ គ្រប់យ៉ាងឲ្យបានហើយរៀបរយមុនព្រះអាទិត្យរះពុំនោះទេ នឹងទទួលទណ្ឌកម្មបង្អត់អាហារ។

ដូច្នោះហើយនារីនេះមិនអាចសម្រាកពេញលេញដូចគេឯងនោះទេ។

អធិរាជក្មេងកាលណាបានយល់រឿងនេះហើយ រកតែនឹងកាត់ចិត្តដូចម្តេចមិនបាន ចង់តែរកយុត្តិធម៌ឲ្យអ្នកនាងអភ័ព្វនៃត្រកូលមួយនេះ ភ្លាមៗក៏ព្រះចៅបានបង្គាប់ទៅកាន់មនុស្សជំនិតថា ចូរឯងទៅគោះទ្វារហើយហៅឱ្យឪពុករបស់នាងចេញមកជួបយើង។

នៅពេលនោះហើយ មេទ័ពក៏បានធ្វើតាមបញ្ជា ដោយមានព្រះរាជាយាងទៅតាមពីក្រោយ។ ពេលដែលគោះទ្វារប្រាប់ហើយ អ្នកដែលបើកទ្វារចេញមកគឺជាអ្នកយាមវ័យចំណាស់មួយរូបគាត់បានប្រាប់ទៅបុរសចម្លែកទាំងពីរថា អ្នកមិនអាចសុំផ្ទះគេស្នាក់នៅបាននោះទេ ដោយសារថាម្ចាស់ផ្ទះមានជំងឺមិនអាចទទួលភ្ញៀវបានឡើយ។

ម៉្លោះហើយមេទ័ពក៏ងាករង់ចាំព្រះរាជឱង្ការពីព្រះមហាក្សត្រ បានហុចរបស់មួយទៅឲ្យអ្នកយាមទ្វារហើយប្រាប់ទៅកាន់អ្នកនោះថា ចូរឯងយករបស់នេះទៅប្រគល់ដល់ម្ចាស់ប្រុសរបស់ឯង ហើយគេក៏នឹងទទួលយើងចូលទៅក្នុងជាមិនខាន។

អ្នកបម្រើអ្នកយាមទ្វារមិនដែលបានឃើញរបស់អ្វីមួយដែលច្នៃឡើងដោយមាសសុទ្ធនា្ទល នឹងធ្ងន់បែបនេះ ថែមទាំងមានឆ្លាក់ជាអក្សរបុរាណដ៏ហិណ្ឌដ៏ចម្លែកដូច្នេះឡើយ ក៏បានឱន លំទោនជាមួយការរណប ហើយថយទៅជាប្រញាប់តាមបញ្ជា។

អ្នកនោះរត់ទៅដល់ចៅហ្វាយប្រុសរបស់ខ្លួនដែលកំពុងអង្គុយសប្បាយរីករាយជាមួយនឹង ភរិយាស្រស់ស្អាតពីររូបនៅក្រោមពន្លឺព្រះចន្ទ។

មុនដំបូងអ្នកយាមត្រូវបានស្តីបន្ទោសថា តើឯងមិនឮយើងប្រាប់ថានេះគឺជាពេលវេលា ហាមឃាត់មិនឱ្យមកប្រាប់យើងអ្វីទាំងអស់ព្រោះយើងនឹងមិនព្រមទទួលព័ត៌មានអ្វីពីអ្នកណា មិនទទួលភ្ញៀវចូលមក ថែមទាំងមិនចង់ដឹងឮរឿងអ្វីទាំងអស់រហូតដល់ថ្ងៃរះ។

អ្នកយាមថាក៏ប៉ុន្តែលោកម្ចាស់ជាទីគោរព របស់មួយនេះមានម្ចាស់របស់គេនៅរង់ចាំខាង ក្រៅហើយថែមទាំងសន្យាផងដែរថា ដរាបណាលោកម្ចាស់បានឃើញប្រាកដណាស់នឹង អញ្ជើញគេចូលមកក្នុង បុរសចំណាស់បានដកខ្លួនចេញពីរាងកាយប្រពន្ធចុងដ៏ស្រស់ស្អាតទាំង ពីរហើយទទួលយកគ្រឿងអលង្ការ ដែលមើលទាំងភ្ញាក់ផ្អើលខ្លាំង។

គាត់លាន់មាត់ថានេះសមថាជារបស់បុរាណមានតម្លៃហួសហេតុនិងជារាជ្យទ្រព្យ ឬមួយ ព្រះចៅអធិរាជឈ្មោះសឹក ពិតជាបានឆ្លងកាត់ភូមិដ្ឋាននេះដោយស្ងាត់ៗមិនឱ្យអ្នកណាដឹង?

លើផ្ទួងសក់នេះមានទំហំប្រមាណជាពាក់កណ្តាលបាត់ដៃមនុស្ស និងឆ្លាក់ទៅដោយអក្សរ បុរាណធំមួយតែប៉ុណ្ណោះ មិនដឹងជាអក្សរតណ្ហាឬក៏អក្សរផ្កាហេតុអ្វីវាធ្ងន់ខ្លាំងសឹងចង់បានមក ជាកម្មសិទ្ធិខានមិនកើត?

ចំណែកក្បួនមាសសុទ្ធ និងក្បាច់នានាអមសងខាងនៃតួអក្សរបានធ្វើឲ្យគាត់ជក់ចិត្តពិនិត្យ មិនអស់មិនហើយ។

ទីបំផុតរកម្ចាស់ប្រុសល្មោភយស បានស្ទុះក្រោកពីកៅអីហើយចាកចេញទៅទ្វារធំដោយ មិនមានស្រដីអ្វីទៅរកអ្នកយាមទេ ទុកឱ្យគូលីរត់ទៅតាមមើលដែរ។

ចំណែកនារីទាំងពីរបានត្រូវគាត់បណ្តេញឱ្យវិលត្រឡប់ទៅកាន់បន្ទប់សម្រាកវិញ។

មកដល់មាត់ទ្វារកាលណាបុរសចំណាស់បានសម្លឹងអ្នកចំណូលថ្មី ទាំងពីរដែលគាត់ ប្រាកដក្នុងចិត្តថា មិនដែលឃើញឆ្លងកាត់ភូមិនេះសូម្បីតែម្តងណាតាំងពីពេលដែលគាត់កើត មក ពិតណាស់ថារូបរាងនិងខោអាវពួកគេតុបតែងបន្លំយ៉ាងណានៅតែមិនអាចលាក់កំបាំង

ឬកពាមានឫទ្ធានុភាព ទាក់ទាញចិត្ត រឹតតែធ្វើឲ្យគាត់ត្រូវពិនិត្យពីលើដល់ក្រោមយ៉ាងយកចិត្តទុកដាក់ហើយសួរថា៖

«តើអ្នកណាម្នាក់ដែលជាម្ចាស់របស់នេះ?»

«គឺយើង!»

ព្រះអង្គបានឆ្លើយក្នុងវាចារាស្ត្រសាមញ្ញក៏ប៉ុន្តែ បុរសម្ចាស់ផ្ទះបានពិនិត្យហើយឱនលំទោនទាបឡើងៗ ព្រមទាំងយាងព្រះអង្គចូលទៅក្នុងផ្ទះធំកាត់តាមសួនច្បាស់ក្រអូបប្រហើរ ដោយវាចាដូច្នេះថា៖

«អូ លោកមន្ត្រីធំ សភាពរបស់លោកគឺជាមន្ត្រីមកពីរាជវាំងអធិរាជ ប៉ុន្តែតើលោកមន្ត្រីធ្វើដំណើរទៅណាមកណា បានជាមិនទៅតាមក្បួនដែលព្រះចៅអធិរាជបានយាងត្រឡប់មកពីសមរភូមិបែរជាមកដល់ភូមិដ្ឋាននេះ?»

ព្រះចៅអធិរាជបានឆ្លើយថា៖

«យើងបានឮគេប្រាប់ថា នៅទីនេះមាននារីដ៏ល្អមួយរូបដែលចេះត្បាញមិនសម្រាក ចាប់តាំងពីព្រលប់រហូតដល់ព្រលឹមក៏ព្រោះតែចង់ផ្គាប់ចិត្តម្ដាយចុងទាំងពីររបស់នាង ដូច្នេះយើងមិនអស់ចិត្តសោះបានជាចង់សុំការអនុញ្ញាតមកពិនិត្យមើលថាតើពាក្យចចាមអារ៉ាមនេះគឺជាការពិតដែរឬទេ»

ថាចប់ព្រះអង្គដើរនាំមុខទៅរ៉ុយសំដៅខ្ទមតូច កៀនរបងធំ មានបុរសចូលផ្ទះចំណាស់បានរត់ទៅត្រុកៗតាមពីក្រោយ ព្រមទាំងពន្យល់ថា នៅក្នុងផ្ទះនេះមិនមានរឿងកើតឡើងដូចដែលលោកមន្ត្រីបានឮនោះទេ។

យប់នោះពេលព្រះចៅអធិរាជបានចចេសទៅដល់ខ្ទមរខេករខាក ក៏ជួបនាងតម្បាញ

សាវ៉ាឌី ឃើញផ្ទាល់នឹងភ្នែកថានាងមានជីវិតស្លៀកពាក់ក្រខ្សត់ និងធ្វើការធ្ងន់ធ្ងរដល់ស្គមកំប្រឹងៗ ក៏ដាក់ទណ្ឌកម្មឪពុកនិងម្ដាយចុងឱ្យមកអង្គុយត្បាញគ្រប់បីឆ្នាំ មិនឱ្យសម្រាកយប់ មិនឱ្យហូបបាយឆ្អែត ហើយលើកនាងជាព្រះមហេសីយាងទៅសោយសុខក្នុងបរមរាជវាំងជាមួយទ្រង់អំណើះតទៅ។

ពេលនិយាយចប់ មេរូបានយល់អំពីសេចក្ដីស្នេហានិងការពិត ដែលបានបំបែកនាងនិងក្សត្រខ្មៅចេញពីគ្នា។ នាងពិតជាអាណិតខ្លួនឯង ដែលមានអតីតកាលជាមួយឪពុកមិនល្អនិង

មានម្តាយចុងជាបិសាច ចុងក្រោយក៏មានវាសនាបានជួបនឹងកំពូលបុរស តែគេបែរជាស្លាប់ចោលហើយតាមរកគ្នាទម្រាំប្រទ្រះឃើញគ្នារហូតដល់ពេលនេះ។

«តើអ្នកណាជាអ្នកសម្លាប់ព្រះអង្គ? ហេតុអ្វីបានជាយើងត្រូវព្រាត់ប្រាសគ្នាតាមរបៀបនេះ?»

«វាគឺជាវេនកម្ម! យើងក៏មិនដឹងថាអ្នកដែលជាធ្វើនោះជាអ្នកណាដែរ បានត្រឹមយើងសន្យានឹងខ្លួនឯងថា នឹងមិនទៅចាប់ជាតិស្រុកនោះទេ ប្រសិនយើងមិនបានជួបគ្នានិងមហេសីយើងសាវ៉ាឌីនេះ!»

«ខ្ញុំនឹងសម្រេចចិត្តថាខ្ញុំនឹងទៅជាមួយអ្នក ប្រសិនបើអ្វីគ្រប់យ៉ាងដែលអ្នកបានប្រាប់មកជាការពិតថា ខ្ញុំនេះជាកូនស្រីនៃផ្ទះមួយនោះ!»

គ្រានោះនាងបានដឹងដំណើរដើមទងថា អង្គក្សត្រាដែលមានរូបរាងស្រស់ស្អាតប្រៀបដូចការស្រមៃរបស់នាងនៅក្នុងរឿងនិទាន មានរូបខ្មៅតែពេលណាមានការរំលោភបំពាននគរ ខឹងសម្បាឬចេញធ្វើសង្គ្រាមទេព្រោះនោះគឺជាវិញ្ញាណនៃអង្គសម្រិត ចំណែកឯភ្នែកត្បូងខៀវដែលជាតំណពូជពង្សអ្នកចម្បាំងរបស់ អាណាចក្រចាស់។

ច្រើនរយឆ្នាំមកហើយអធិរាជនៅសំងំរង់ចាំមហេសីនៅក្នុងប្រាសាទនោះ បើមិនដែលឃើញភរិយាមកដល់ទេ នឹងមិនព្រមចាកចេញទៅណាឡើយ មិនព្រមរំងាប់ចិត្ត រហូតដល់ព្រឹកម្សិលមិញនេះទ្រង់បានឮសំឡេងនាង ក៏តើនឡើងពីការគេង១០០០ឆ្នាំ នឹងដឹងថាវេលាដែលត្រូវបានជួបគ្នា បង្វិលមកដល់វិញហើយ។

ចាប់ពីដឹងរឿងទាំងអស់កាលពីអតីតកាលដ៏កំសត់ ហើយមេរូស្រាប់តែកើតចិត្តរំភើបចាត់ទុកគេនោះជាប្តីរបស់នាងពិតៗ នឹងបានអង្វរគេធ្វើយ៉ាងណាកុំធ្វើឲ្យម្តាយនិងបងប្រុសនាងរងបញ្ហាអ្វី។

«ពួកគេសន្លប់ហើយ! តែយើងសន្យាថានឹងជួយពួកគេឱ្យរស់នៅបានល្អដរាបណាអូនព្រមទៅជាមួយបង!»

មេរូបានចេញមកក្រៅឃើញពួកគេកំពុងលង់លក់ក្រោមមន្តអាគម។

នាងយំហើយនិយាយប្រាប់ថាមនុស្សស្រីត្រូវតាមប្តី។ ស្វាមីជាក្សត្រាបានស្ម័គ្រដាក់ទារុណកម្មខ្លួនឯងឯកោក្នុងប្រាង្គប្រាសាទចាស់រង់ចាំនាងពាន់ឆ្នាំមកហើយពេលនេះទម្រាំបានជួបគ្នាវិញ  នាងចាំបាច់ត្រូវទៅបន្តចំណងនិស្ស័យស្នេហ៍ចាស់ជាមួយទ្រង់។

លាម្ដាយហើយកាលណា ស្ដេចបាននាំនាងរំលេចទៅដល់ក្នុងប្រសាទនោះវិញភ្លាមៗ ហើយបង្ហាញចេញនូវក្លោងទ្វារមួយចូលទៅវិញជាមួយគ្នាក្នុងភពអតីតកាល។

ដឹងអីថា ពេលទ្រង់ដឹកដៃព្រះមហេសីឈានដល់មាត់ទ្វារ មានតែអង្គក្សត្រប៉ុណ្ណោះដែលអាចឈានចូលឆ្លងភពទៅបាន ប៉ុន្ដែមេរូមិនអាចទេ នាងបានត្រឹមក្ដៅរោលរាលក្ដៅស្រែកយំរើងរៃនៅទីនោះ។ សណ្ឋាននាងដូចត្រូវអគ្គីដុតទាំងរស់រាល់ពេលឈានចូលទៅម្ដងៗ ម៉្លោះហើយទោះប្ដីប្រពន្ធ បានខិតខំយ៉ាងណានៅតែជម្ទះចូលទ្វារនោះវិញមិនបានដដែលជាដដែល។

ចាប់ពីពេលនោះមក ជារៀងរាល់ថ្ងៃគូស្នេហ៍បានណាត់ជួបលួចជួបរួមមេត្រីជាមួយគ្នានៅក្នុងបន្ទប់គេងនាង លាក់កំបាំងមិនឲ្យអ្នកណាដឹងទាំងអស់។

មេរូបានប្រាប់ម្ដាយថានាងមិនបាច់ទៅស្រុកកំណើតព្រោះសុខភាពមានគ្មានបញ្ហាអ្វីនោះទេដោយសារតែនាងប្រើថ្នាំងងុយគេងច្រើនពេកតែប៉ុណ្ណោះ។

ដោយសារម្ដាយរបស់នាងសង្កេតឃើញគឺថានាងហាក់សប្បាយរីករាយច្រើនជាងមុនជាខ្លាំង ដូច្នេះហើយគាត់បានសម្រេចចិត្តក៏វិលទៅស្រុកកំណើតវិញទុកឱ្យមេរូនៅស្នាក់ទីនេះដើម្បីបន្ដការសិក្សារបស់នាង។

រយៈពេលនោះមីងជាបងប្រុសជីដូនមួយកម្រណាស់ដែលមានពេលជួបជជែកសុខទុក្ខឬអ្វីផ្សេងជាមួយនឹងមេរូពីព្រោះនាងមានសភាពតែងតែប្រញាប់ប្រញាល់វិលត្រឡប់ទៅផ្ទះដូចជាមានអ្នកណាម្នាក់កំពុងរង់ចាំ។

មិនយូរប៉ុន្មាន មេនសាបានត្រឡប់មកវិញក្រោយបុណ្យទានម្ដាយចប់។

ប៉ុន្ដែមេនសាចាប់អារម្មណ៍ថាមេរូមិនសូវមានពេលរាក់ទាក់ជាមួយដូចកាលពីមុននោះទេដោយសារតែនាងតែងតែមានអារម្មណ៍ស្ងាត់ស្ងៀម និងចង់មានភាពឯកជន។

មិនយូរទេ ថ្ងៃមួយនោះបានកើតឡើងដោយមេរូបានស្នើសុំឱ្យមេនសារើចេញ ដោយអះអាងថានាងមានសង្សាររួចហើយ ដូច្នេះនាងសុំនៅតែពីរនាក់គេនៅក្នុងនេះ។

មេនសាមានការអាក់អន់ស្រពន់ចិត្តជាខ្លាំង ដោយម្ដាយខ្លួនទើបនឹងស្លាប់ ចំណែកឯ

មិត្តភក្ដិក៏ស្រាប់តែបោះបង់ខ្លួនចោល ទោះចាកចេញមកមែនតែនាងមិនអស់ចិត្តនឹងអាកប្បកិរិយាចិត្តដាច់របស់មេរូទេ។

ថ្ងៃមួយមេនសាបានជួបមីនដោយចៃដន្យនៅសាលា។ មេនសាបានចូលទៅនិយាយជាមួយមីនថា ឱ្យមីនតាមមើលមេរូផង ដោយសារមេនសាចាប់ផ្តើមឃើញមេរូផ្លាស់ប្តូរឥរិយាបថ ក្លាយទៅជាមនុស្សដែលមានភាពអាត្មានិយមខ្លាំង មិនមានលក្ខណៈដូចជាមេរូពីមុនឡើយដែលជាមនុស្សស្មោះត្រង់ រាក់ទាក់និងឈឺឆ្អាលចំពោះមិត្តភក្តិ។

ដំបូងមីនស្តាប់ហើយ ចិត្តមួយលបគិតថាប្រហែលមកពីមេនសាខឹងដែលមេរូបានបណ្តេញឲ្យលែងស្នាក់នៅបន្ទប់របស់នាង ប៉ុន្តែចិត្តមួយទៀតមីនក៏គិតថានឹងតាមដានមើលសភាពរបស់មេរូដែរ ដូច្នេះហើយមីននខលទៅប្អូនស្រីថា ៖

«អូ៎ ក្រុមបងនឹងមានដំណើរកម្សាន្តមួយទៅឆ្ងាយ ហើយនៅទីនោះមានប្រាសាទពីរកន្លែងមានប្រវត្តិអស្ចារ្យណាស់ តើឯងចង់ទៅដែរទេមេរូបងចុះឈ្មោះឱ្យ!»

«ខ្ញុំមិនទៅទេខ្ញុំមានការងារធ្វើច្រើនណាស់!»

«មួយរយៈនេះឯងដូចជារវល់ខ្លាំងម្ល៉េះ ឯងរវល់ធ្វើការអ្វីខ្លះ បងឆ្ងល់នឹងឯងដែរ?!»

«បងឯងណាស់ដឹងទេថាខ្ញុំរវល់ប៉ុណ្ណឹងទៅបានហើយ»

«ចុះមានទាក់ទងអ្វីនឹងបងឯង បើមានការអីចាំខ្ញុំខលទៅទៀត ប៉ុណ្ណឹងហើយ!»

«ឈប់សិនៗៗៗ មេរូ! គ្រប់គ្នាគិតថា ឯងមួយរយៈនេះមានរឿងអ្វីអាថ៌កំបាំងចម្លែកៗម្ល៉េះ? តាំងពីឯងដេញមេនសាចេញ តើឯងទៅសេពគប់អ្នកណា ហេតុអ្វីចុងក្រោយនេះមេរូផ្តាច់ខ្លួនចេញពីមិត្តចាស់ៗដែលធ្លាប់តែទុកចិត្តគ្នាបាន?»

«មេនសានិយាយមែនទេ? បានហើយខ្ញុំចង់និយាយរឿងនេះទេ! បងឯងត្រូវមានអីធ្វើផ្ទាល់ខ្លួនធ្វើទៅហើយគោរពជីវិតផ្ទាល់ខ្លួនរបស់អ្នកដទៃផង!»

នាងបានដាក់ទូរសព្ទចុះ ហើយចូលទៅក្នុងបន្ទប់ទាំងញញឹមព្រោះក្បត្រាភ្នែកខៀវតែងតែមានវត្តមាននិងរង់ចាំថ្នមថ្នាក់មេរូគ្រប់ពេលវេលាធ្វើឱ្យពួកគេ បន្តរស់នៅជាប្តីប្រពន្ធនឹងគ្នានៅក្នុងបន្ទប់នេះធ្វើដូចលោកនេះមានតែគេពីរនាក់។

ព្រលឹមឡើងនាងក្រោកពីដំណេកយឺតយ៉ាវដូចរាល់ ស្រាប់តែនាងត្រូវរន្ធត់ដោយសារតែដំណឹងមកថា មេនសាត្រូវរបួសធ្លាក់ពីលើជណ្តើរនៅពេលនាងកំពុងធ្វើកម្មសិក្សានាតំបន់ទេសចរមួយ។ មេរូអានព័ត៌មាននេះនៅក្នុងហ្វេសប៊ុកទាំងអារម្មណ៍សង្ស័យ។

ដោយទ្រាំមិនបាននាងក៏ចូលបន្ទប់ហើយស្រែករកស្វាមីរបស់នាងទាំងខឹងថា តើអ្នកមែនទេដែលធ្វើឲ្យមិត្តរបស់ខ្ញុំធ្លាក់ពីលើជណ្តើរ?

ក្សត្រាខ្មៅបានបង្ហាញខ្លួនតាមកញ្ចក់និយាយសារភាពប្រាប់នាងថា៖

«អ្នកណាក៏ដោយដែលធ្វើឲ្យប្រពន្ធរបស់យើងមិនសប្បាយចិត្ត យើងអាចនឹងធ្វើអ្វីច្រើនជាងនេះទៀតទៅកាន់ពួកគេ។»

«ឈប់ធ្វើបែបនេះទៅ! ខ្ញុំកំពុងរស់នៅក្នុងឋានមនុស្សដែលមានច្បាប់ហើយមានគុណធម៌! អ្នកមិនអាចធ្វើអ្វីៗទៅកាន់អ្នកដទៃ ដែលគេគ្មានកំហុសចំពោះអ្នកនោះទេ! បើសិនណាអ្នកមិនឈប់ប៉ះពាល់មនុស្សទាំងអស់ និងឈប់បង្កើតការឈឺចាប់ចំពោះពួកគេ ខ្ញុំនឹងចាកចេញពីអ្នកភ្លាម!»

សម្តីមេរូធ្វើឱ្យស្តេចនោះកើតជាក្តីខឹងសម្បាយ៉ាងខ្លាំងក៏លើកចង្អុលដៃចុចអាគមឱ្យខ្មៅចខ្មីបង្ហួចនិងផ្ទាំងកញ្ចក់ទាំងអស់ដែលនាងមាន ធ្វើឲ្យមេរូស្រែកយំយ៉ាងខ្លាំង។

ស្តេចនោះរលាយបាត់ទៅកាលណា មេរូចង់ទូរសព្ទរកមីនមកជួយដោះស្រាយបញ្ហានៅទីនេះជាមួយនាង ប៉ុន្តែនៅពេលដែលម្រាមដៃប៉ះដល់ប្រអប់ទូរសព្ទកាលណា មេរូចាប់អារម្មណ៍ឃើញថា អ្នកណាក៏ដោយបើសិនជានាងកាន់តែមានពាក់ព័ន្ធជាមួយជិតដិតក៏នឹងអាចធ្វើឲ្យក្សត្រាភ្នែកត្បូងខឹងសម្បាដល់ពួកគេ ហើយនាងក៏មិនដឹងទេថា មានអ្វីកើតឡើងចំពោះគេទៀត។

យប់នោះនាងចាប់ផ្តើមយំសោកដាក់ស្វាមីរបស់នាងនៅលើគ្រែដំណេកថា៖

«បើត្រូវរស់នៅនាំទុក្ខលំបាកដល់អ្នកដទៃឬត្រូវឯកោដូច្នេះដដែល ដូច្នេះខ្ញុំនឹងសម្លាប់ខ្លួនឲ្យស្លាប់ទៅនៅជាមួយអ្នក កុំឱ្យអ្នកដទៃមានបញ្ហាចំពោះខ្ញុំទៀត! ព្រោះឥឡូវនេះសូម្បីតែខ្ញុំទៅលេងម្តាយពុកខ្ញុំក៏អ្នកមិនអនុញ្ញាត ការសិក្សាខ្ញុំបរាជ័យ ឲ្យខ្ញុំមិនដឹងថានឹងមានរឿងអ្វីចំពោះពួកគេទៅមុខទេ។»

ក្សត្រាបាននិយាយថា៖

«បងមិនដឹងថា តើហេតុអ្វីបានជាព្រលឹងយើងទាំងពីរមិនអាចពាក់ព័ន្ធជាមួយគ្នាខ្លាំងទាំងបងចង់នាំអូនទៅកាន់ប្រាសាទចាស់និងរស់នៅក្នុងកន្លែងរបស់យើង ប៉ុន្តែហេតុអ្វីមិនជាបងនៅតែមានអារម្មណ៍ថាមាននរណាម្នាក់បានដាក់បណ្តាសាអ្វីមួយមកយើង»

មេរូមានការងឿងឆ្ងល់ជាខ្លាំង នាងងើបមុខសម្លឹងព្រះអង្គម្ចាស់ហើយសួរថា៖

«តើបណ្ដាសាអ្វីទៅ?»

«បងបានស្បថថា ជាតិណាក្ដីបងនឹងអាចនាំតែមនុស្សស្រីម្នាក់ដែលជាភរិយាពិតរបស់បងចូលទៅក្នុងប្រាសាទចាស់ រស់នៅអស់កប្បជាមួយគ្នាជារៀងរហូតតទៅ មិនរវល់នឹងពិភពខាងក្រៅ ប៉ុន្តែហេតុអ្វីបានជានៅជាមួយអូន បងមិនអាចនាំមេរូទៅកាន់ច្រកទ្វារចូល ប្រាសាទដើមនោះបាន? ហេតុអ្វីទៅ? បងកំពុងតែស្វែងរកនូវគន្លឹះនៃអាថ៌កំបាំងនេះដើម្បីបំបែកវា!»

ឮពាក្យនេះហើយមេរូក៏រំសាយកំហឹង ហើយនៅយប់ដដែលនោះនាងចាប់ផ្ដើមលង់លក់ស្កប់ស្កល់ ប៉ុន្តែមិនយូរប៉ុន្មានសុបិនដ៏អាក្រក់មួយបានលងបន្លាចវិញ្ញាណរបស់នាង។ មេរូបានយល់ខ្លួនឯងស្ថិតនៅកណ្ដាលលំហូរទឹកពណ៌ខ្មៅនិងរលកធំៗ មើលមិនឃើញកោះត្រើយ មិនដឹងថាជាទន្លេឬសមុទ្របឹងបួរ បានត្រឹមថប់ដង្ហើមនិងឈានជើងមិនរួចជាប់គាំង ដូចមនុស្សលិចខ្លួនក្នុងទឹក ក៏អ្វីប៉ុន្តែរកសម្គាល់ទិសដៅនិងហែលទៅរកសង្គ្រោះជីវិតមិនបាននោះទេ។

នៅពេលដែលនាងកំពុងភ័យស្លន់ ភ្នែកទី៣ របស់នាងនៅចំកណ្ដាលថ្ងាសបញ្ចេញភ្លើងក្ដៅរោលដែលអាចបង្ហាញនូវពន្លឺធ្វើឱ្យមេរូឃើញផ្លូវ និងខំហែលឆ្ពោះទៅរកច្រាំងថែមទាំងបានក្រោកឈរមកតវ៉ាឮៗថា៖

«នៃទឹកខ្មៅ តើអង្គឯងជាបិសាចខាងណាហេតុអ្វីបានជាឯងមកនៅក្នុងសុបិនរបស់យើង ឬក៏ឯងជាសត្រូវនៃស្វាមីរបស់យើងជាអធិរាជ ហើយឯងកើតច្រណែនដែលយើងនិងស្វាមីបានជួបជុំគ្នាវិញ?»

ភ្លាមនោះផ្ទៃទន្លេពណ៌ខ្មៅបានរមួលខ្នាញ់មុនពេលស្រែកតបមកវិញជាសំឡេងមនុស្សស្រីថា៖

«ចូរឯងឈប់កុហកខ្លួនឯងទៅនាងមេត្រាវ៉ារី! នាងមិនមែនជាប្រពន្ធរបស់ស្ដេចបងឡើយ! យើងទេទើបជាភរិយារបស់គេ! នាងមិនអាចឈានចូលទៅក្នុងប្រាសាទចាស់អតីតរាជវាំងរួមរស់ជាមួយនឹងស្វាមីរបស់យើង ព្រោះនាងបន្លំជាព្រះមហេសី! ថ្ងៃណាមួយនាងនឹងបានទទួលកម្មរបស់នាងជាក់ជាមិនខានទេ!»

ភ្លាមនោះទឹកបានច្របូកច្របល់បំបោលឡើងមកខ្ពស់សន្ធៅបំណងបំបុករាងកាយមេរូធ្វើឲ្យនាងត្រូវដួលបះជើងទាំងមិនដឹងខ្លួន និងបាត់ជំហរទៅក្នុងការចុះចាញ់។ មិនយូរប៉ុន្មាននាងឃើញមេឃដ៏ងងឹតនៅខាងលើក៏សម្លក់មកចង់សន្ធប់ជីវិតនាងដែរ នាងក៏ខំស្រែកហៅស្វាមីឲ្យ

បង្ហាញខ្លួនឆាប់រ៉ា ភ្លាមនោះស្តេចអង្គខ្មៅបានត្រឡប់មកដល់ហើយសួរនាងថាតើមានអ្វីកើតឡើង? មេរូបានយំសោកហើយតបថា តើអ្នកណាទៅឈ្មោះថាមិនត្រាវ៉ារី?

ស្តេចឮឈ្មោះនេះកាលណាក៏បើកភ្នែកធំៗសម្លឹងនាងហើយនិយាយឡើងថា ហេតុអ្វីបានជាអូនសួររកស្រីកំណាចនោះ?

ខ្ញុំមិនដឹងទេ ខ្ញុំយល់សប្តិឃើញមានផ្ទៃវ៉ារីខ្មៅងងឹតឥតសង្ឃឹមមួយ វាចេះនិយាយសំឡេងជាមនុស្សស្រី ហើយស្រែកយំតវ៉ាទាមទារថា គេទើបពិតជាប្រពន្ធរបស់អ្នកចំណែកខ្ញុំមានឈ្មោះថា មិនត្រាវ៉ារី។